00380872

ឯកសារ/លំ: D97/9/6

នៅចំពោះមុខអង្គបុរេជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de réception): 25 / 09 / 2009
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ ៖ សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន ៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម ៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ ៖ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន ៖

ឈ្មោះមន្ត្រីកត់ត្រា ៖

ហត្ថលេខា ៖

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងសំណើសុំឲ្យដាក់ឧបសគ្គកម្មប្រឆាំងនឹងសហព្រះរាជអាជ្ញាចំពោះការចោទប្រកាន់ថាបំភ័ន្តតុលាការពាក់ព័ន្ធទៅនឹងច្បាប់ស្ដីពីសហកម្មវត្ថុក្រិដ្ឋកម្មរួម**

---

| **ដាក់ដោយ** ៖ | **ផ្ញើជូន** ៖ | **ផ្ញើជូន** ៖ |
|---|---|---|
| **សហមេធាវី ៖** | **សហចៅក្រមស៊ើបអង្កេត ៖** | **សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ៖** |
| លោក អាង ឧត្តម | ចៅក្រម យូ ប៊ុនឡេង | David BLACKMAN |
| លោក Michael G. KARNAVAS | ចៅក្រម Marcel LEMONDE | ឡោ ជុនធី |
| | | គីម ម៉េងឃី |

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារ/លេខ: ៥97/9/6



នី ចាន់ឌី

Martine JACQUIN

Philippe CANNONE

Fabienne TRUSSES-

NAPROUS Annie DELAHAIE

ហុង គីមសួន

គង់ ពិសី

យុង ផានិត

ម៉ុច សុវណ្ណារី

ស៊ិន សាវ៉ន

Silke STUDZINSKY

Pirre-Olivier SUR

Olivier BAHOUGNE

Marie GUIRAUD

Patrick BAUDOIN

Mahdev MOHAN

Lyma NGUYEN

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក William SMITH

ឯ/ល: D97/9/6



អនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("ក្រុមមេធាវីការពារក្តី") សុំដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី (**"ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី"**)[1] ទៅនឹងសំណើរបស់លោក អៀង សារី សុំឲ្យដាក់ទណ្ឌកម្ម តាមវិធានផ្ទៃក្នុង ៣៥ ចំពោះសហព្រះរាជអាជ្ញាដែលបំភ័ន្តតុលាការនៅក្នុង **សេចក្តីសង្កេតបន្ថែម** របស់ពួកគាត់ស្តីពីច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ដែលបានដាក់កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨ (**"សំណើសុំដាក់ទណ្ឌកម្ម"**)[2]។ ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានថ្លែងប្រាស្រ័យអំពីបញ្ហាសំខាន់ ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីនៅក្នុងសំណើសុំដាក់ទណ្ឌកម្មរបស់ក្រុមមេធាវីការពារក្តីនោះទេ និងបានលើកឡើងនូវទស្សនៈករណ៍ពុំត្រឹមត្រូវនិងនាំឲ្យមានការយល់ខុសមួយចំនួន។ ថ្វីបើគ្មានការអះអាងណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឲ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានស្របច្បាប់ដែលកំណត់ឡើងដោយក្រុមមេធាវីការពារក្តី ចម្លើយតបវិញនេះមានលក្ខណៈចាំបាច់គឺដើម្បីបញ្ចៀសនូវការភ័ន្តច្រឡំណាមួយ ចំពោះបញ្ហានានាដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី។

## I. សេចក្តីសង្ខេបទឡ្ហីករណ៍

១. ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ក) របាយការណ៍របស់ គណៈកម្មការច្បាប់ អន្តរជាតិ ទទួលស្គាល់ថា ការទទួលខុសត្រូវផែនការរួមគឺជាផ្នែកនៃគោលការណ៍របស់តុលាការ Nuremberg[3] ខ) ក្រុមមេធាវីការពារក្តីបានដកស្រង់របាយការណ៍របស់ Spiropoulos ដែលថា ប្រសិនណាវាជារបាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ ("ILC") ក្តី ក៏តាមរយៈនោះ បានបណ្តាលឲ្យក្រុមមេធាវីការពារក្តី "រំលងទាំងស្រុង" នូវគោលការណ៍ VII ដែលបង្ហាញថា

---

[1] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ00២/១៩-0៩-២00៧-អ.វ.ត.ក/ក.ស.ច.ស, ចម្លើយរបស់មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី ទៅលើពាក្យសុំរបស់ អៀង សារី ស្នើសុំដាក់ទណ្ឌកម្មប្រឆាំងនឹងសហព្រះរាជអាជ្ញា ដែលបានបំភ័ន្តតុលាការ ទាក់ទងនឹងច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២00៩។

[2] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ00២/១៩-0៩-២00៧-អ.វ.ត.ក/ក.ស.ច.ស, សំណើរបស់លោក អៀង សារី សុំអោយ ដាក់ទណ្ឌកម្មតាមវិធានផ្ទៃក្នុង៣៥ ដោយសារសហព្រះរាជអាជ្ញា បានបំភ័ន្តតុលាការនៅក្នុងការដាក់សេចក្តីសង្កេតបន្ថែមស្តីពី សហកម្មឧក្រិដ្ឋកម្មរួម ដែលបានដាក់ធ្វើនៅថ្ងៃទី ៣១ ធ្នូ ២00៨, ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២00៨, ឯកសារលេខ D97/9 ERN 00345986 ។

[3] ចម្លើយរបស់សហមេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ៣-៥។

របាយការណ៍ ILC បានទទួលស្គាល់ការទទួលខុសត្រូវផែនការរួម[4] គ) របាយការណ៍របស់ Spiropoulos ទទួលស្គាល់ការទទួលខុសត្រូវផែនការរួម[5] និង ឃ) ការតាក់តែងរូបមន្តនៃគោលការណ៍នានាដែលបានកំណត់នៅក្នុងរបាយការណ៍របស់ Spiropoulos ពុំមានអំណាចតាមផ្លូវច្បាប់នោះទេ ហើយសេចក្តីសម្រេចរបស់ ILC ដែលត្រូវរួមបញ្ចូលនូវគោលការណ៍ VII បង្ហាញថា ILC បានចាត់ទុក ការទទួលខុសត្រូវផែនការរួម ថាជាផ្នែកមួយនៃគោលការណ៍នានារបស់តុលាការ Nuremberg[6]។

២. ក្រុមមេធាវីការពារក្តីនឹងបង្ហាញថា ៖

ក. ដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានបង្ហាញនូវបញ្ហាស្នូលនៃសំណើសុំដាក់ទណ្ឌកម្មទេ ៖ ការដាក់ទណ្ឌកម្មបានស្វែងរកនោះគឺសំដៅទៅលើសហព្រះរាជអាជ្ញាអន្តរជាតិ ឬ សមាជិកនានានៃការិយាល័យសហព្រះរាជអាជ្ញា ចំពោះការបំភ័ន្តតុលាការដោយគម្រោងទុកជាមុន ដោយមិនធ្វើការបង្ហាញយ៉ាងចេតនានូវសេចក្តីសម្រេច ៤៨៨(v) របស់មហាសន្និបាតអង្គការសហប្រជាជាតិនោះទេ។

ខ. របាយការណ៍របស់ ILC ទទួលស្គាល់ការទទួលខុសត្រូវផែនការរួម *ចំពោះតែ* ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព *ប៉ុណ្ណោះ*។

គ. ការដកស្រង់របាយការណ៍របស់ Spiropoulos ដោយការធ្វេសមិនយកចិត្តទុកដាក់ ថា ប្រសិនណាវាជារបាយការណ៍របស់ ILC ក្តី មិនបានផ្លាស់ប្តូរការពិតដែលថា ពុំមានរបាយការណ៍ណា បានទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម ចំពោះ ឧក្រិដ្ឋកម្មសង្គ្រាម ឬក៏ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នោះទេ។

ឃ. របាយការណ៍របស់ Spiropoulos ក៏ដូចជារបាយការណ៍របស់ ILC ទទួលស្គាល់ការទទួលខុសត្រូវផែនការរួម ចំពោះតែ ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ប៉ុណ្ណោះ។ និង

ង. អង្គហេតុដែលថារបាយការណ៍របស់ ILC រក្សាទុកនូវគោលការណ៍ VII នោះ មិនមានន័យថា វាបានទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម នោះទេ ៖ "អំពើសមគំនិត " នៅ

---

4 *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៥-៦។

5 *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៧-១៣។

6 *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ១៤-១៦។

ក្នុងគោលការណ៍ VII ខុសគ្នាជាសារវន្ត ពី ការទទួលខុសត្រូវផែនការរួម។

## II. ឧត្តិករណ៍

### ក. ដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានថ្លែងប្រាស្រ័យពីទណ្ឌកម្ម ដែលត្រូវបានស្នើសុំប្រឆាំងនឹងការិយាល័យសហព្រះរាជអាជ្ញាចំពោះការបំភ័ន្តតុលាការដោយចេតនា

៣. ចំណុចសំខាន់នៃសំណើសុំដាក់ទណ្ឌកម្ម គឺជាការស្នើសុំឱ្យដាក់ទណ្ឌកម្មប្រឆាំងនឹងការិយាល័យសហព្រះរាជអាជ្ញាចំពោះការបំភ័ន្តតុលាការដោយមានចេតនា ដោយមានបំណងមិនធ្វើការបង្ហាញពីសេចក្តីសម្រេច ៤៨៨(v) របស់មហាសន្និបាតអង្គការសហប្រជាជាតិ។ ក្នុងសំណើសុំដាក់ទណ្ឌកម្ម ក្រុមមេធាវីការពារក្តីបានសំអាងសំណើសុំដាក់ទណ្ឌកម្មរបស់ខ្លួន លើអង្គហេតុដែលថា ក្រមសីលធម៌ ដែលភ្ជាប់តម្រូវការឱ្យសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញាបំពេញតាម ចែងពីកាតព្វកិច្ចក្នុងការបង្ហាញអំណាចដែលមិនសម្តែងសេចក្តីយល់ព្រម ៖ ការបំភ័ន្តតុលាការ ដោយគិតទុកជាមុន និង ដោយចេតនា ត្រូវបានហាមឃាត់។

៤. ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងចម្លើយតបរបស់ខ្លួន មិនបានថ្លែងប្រាស្រ័យពីកាតព្វកិច្ចតាមក្រមសីលធម៌ស្តីពីការបង្ហាញឱ្យឃើញ ដែលត្រូវបានស្នើឡើងដោយក្រុមមេធាវីការពារក្តីនោះឡើយ។ ការខកខានមិនបានថ្លែងប្រាស្រ័យពីបញ្ហាសំខាន់នៃសំណើសុំដាក់ទណ្ឌកម្មនេះ ធ្វើឱ្យមានការសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីពិតជាយល់ស្របថា ការិយាល័យសហព្រះរាជអាជ្ញាបានរំលោភបំពានលើកាតព្វកិច្ចតាមក្រមសីលធម៌របស់ខ្លួន នៅពេលដែលការិយាល័យនេះបានជ្រើសរើស ដោយបានគិតទុកជាមុន មិនបង្ហាញពីសេចក្តីសម្រេច ៤៨៨(v) របស់មហាសន្និបាតអង្គការសហប្រជាជាតិ។

៥. ដើមបណ្តឹងរដ្ឋប្បវេណីផ្តោតយកចិត្តទុកដាក់តែទៅលើបញ្ហាដែលមិនសំខាន់ ស្តីពីការដកស្រង់ខុសទៅវិញ ដែលមិនប៉ះពាល់ដល់សេចក្តីស្នើសុំ ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីតែប៉ុណ្ណោះ ៖ គោលការណ៍របស់តុលាការ Nuremberg មិនរួមបញ្ចូល ការទទួលខុសត្រូវផែនការរួម សម្រាប់ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នោះទេ។

ការ/ស: ៦១៧/១៤



## ខ. របាយការណ៍របស់ ILC ទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម *តែ* ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព *ប៉ុណ្ណោះ*

៦. ដើមបណ្តឹងរដ្ឋប្បវេណីប្រកែកតវ៉ាថា របាយការណ៍របស់ ILC ទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម ថាជាផ្នែកនៃគោលការណ៍នានារបស់តុលាការ Nuremberg[7]។ យ៉ាងណាក្តី គឺវាច្បាស់ក្រឡែត តាមការអានដោយប្រុងប្រយ័ត្ននូវ គោលការណ៍ទាំងប្រាំពីរ ដែលបានរាយនៅក្នុងរបាយការណ៍របស់ ILC ដែលថា ការទទួលខុសត្រូវផែនការរួម ត្រូវបានគិតគូរតែចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ប៉ុណ្ណោះ។

៧. គោលការណ៍ទាំងនេះបានចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធ ៖

*គោលការណ៍ VI ៖* បទឧក្រិដ្ឋទាំងឡាយដែលបានកំណត់ ពីនេះតទៅ អាចដាក់ទោសបានជាបទល្មើសឧក្រិដ្ឋ ក្រោមច្បាប់អន្តរជាតិ ៖

*(ក)* ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ៖

(i) ការធ្វើផែនការ ការរៀបចំ ការផ្តួចផ្តើមគំនិត ឬ ការធ្វើសង្គ្រាមឈ្លានពាន ឬ សង្គ្រាមក្នុងការរំលោភបំពានលើសន្ធិសញ្ញា កិច្ចព្រមព្រៀង ឬ ការធានាវ៉ាប់រងជាអន្តរជាតិនានា។

(ii) <u>ការចូលរួមក្នុងផែនការរួមមួយ</u> ឬ ការសមគំនិតដើម្បីសម្រេចអំពើណាមួយក្នុងចំណោមអំពើ ដែលបានលើកឡើងស្របតាមចំណុច (i)។

*(ខ)* ឧក្រិដ្ឋកម្មសង្គ្រាម ៖

ការរំលោភបំពាននានាទៅលើច្បាប់ ឬ ទំនៀមនៃសង្គ្រាមទាំងឡាយ ដែលរួមបញ្ចូល តែមិនកំណត់ចំពោះ អំពើឃាតកម្មគិតទុកជាមុន ការធ្វើបាប ឬ ការនិរទេសឲ្យទៅធ្វើជាទាសករបំរើការងារ ឬ សម្រាប់គោលបំណងផ្សេងណាមួយ ចំពោះប្រជាជនស៊ីវិលនៃ ឬ នៅក្នុងទឹកដីដែលបានកាន់កាប់ ឃាតកម្មគិតទុកជាមុន ឬ ការធ្វើបាបឈ្លើយសឹក ចំពោះមនុស្សទាំងឡាយនៅតាម

---

[7] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣-៤។

សមុទ្រ ការសម្លាប់ចំណាប់ខ្មាំង ការលួចប្លន់ទ្រព្យសម្បត្តិសាធារណៈ ឬ របស់ឯកជន ការបំផ្លិចបំផ្លាញយ៉ាងព្រៃផ្សៃចំពោះទីក្រុង ទីប្រជុំជន ឬ ភូមិនានា ឬ ការបង្ខិនបង្ខោចដែលមិនត្រូវតែមានសម្រាប់ភាពចាំបាច់ខាងយោធា។

*(គ)* ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖

ឃាតកម្មគិតទុកជាមុន ការសម្លាប់រង្គាល ការដាក់ជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ដទៃៗផ្សេងទៀត ដែលធ្វើឡើងប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិល ឬ ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ ឬ សាសនា នៅពេលណាអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើង ឬ ការធ្វើទុក្ខបុកម្នេញទាំងនេះត្រូវបានអនុវត្ត ជាការប្រតិបត្តិ ឬ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពណាមួយ ឬ ឧក្រិដ្ឋកម្មសង្គ្រាមណាមួយ។

*គោលការណ៍ VII* ៖ អំពើសមគំនិតនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានបង្ហាញនៅក្នុងគោលការណ៍ VI គឺជាបទល្មើសឧក្រិដ្ឋ ក្រោមច្បាប់អន្តរជាតិ[8]។

៨. វាច្បាស់ហើយដែលថា និទ្ទេសអំពី "ការចូលរួមក្នុងផែនការរួម" នៅក្នុងគោលការណ៍ VI គឺទាក់ទងតែទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពប៉ុណ្ណោះ ដោយសារ វាត្រូវបានរាយបញ្ជីដាក់បញ្ចូលតែនៅក្នុងអនុផ្នែកនោះប៉ុណ្ណោះ ហើយមិនបានដាក់បញ្ចូលនៅក្នុងអនុផ្នែកខាងក្រោម ដែលសំដៅទៅចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៩. គោលការណ៍ VII និយាយអំពី "អំពើសមគំនិត" ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ដើមបណ្តឹងរដ្ឋប្បវេណីពឹងផ្អែកលើគោលការណ៍ VII ដោយថ្លែងបញ្ជាក់ប្រយោលៗថា ពាក្យ "ការការទទួលខុសត្រូវផែនការរួម" និង "ការសមគំនិត" ត្រូវបានប្រើផ្លាស់ប្តូរគ្នាបាន។ ការណ៍ដែលគ្រាន់តែថា គោលការណ៍ VI និងគោលការណ៍ VII

[8] របាយការណ៍នៃគណកម្មការច្បាប់អន្តរជាតិ នៅសម័យប្រជុំលើកទីពីររបស់ខ្លួន ពីថ្ងៃទី៥ ខែមិថុនា ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៥០, កំណត់ត្រាផ្លូវការនៃមហាសន្និបាទ សម័យប្រជុំលើកទី៥, សេចក្តីបន្ថែម No.12 (A/1316) ("របាយការណ៍ ILC") (គូសបញ្ជាក់បន្ថែម)។

ប្រើពាក្យពីរផ្សេងខុសគ្នានោះ បង្ហាញថា ការទទួលខុសត្រូវផែនការរួម និង អំពើសមគំនិត មិនមែនជាគោលគំនិតដូចគ្នា និង មិនមែនជាលក្ខខណ្ឌដែលអាចត្រូវប្រើផ្លាស់ប្តូរគ្នាបានឡើយ។

១០. អំពើសមគំនិត ជាគោលទស្សនៈផ្នែកច្បាប់ គឺខុសគ្នាយ៉ាងខ្លាំងពីការទទួលខុសត្រូវផែនការរួម។ ការទទួលខុសត្រូវផែនការរួមតំណាងឱ្យទស្សនៈ នៃ ការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ទោសជាទូទៅច្រើនជាង គឺថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលចំពោះអំពើទាំងឡាយរបស់អ្នកដទៃ[9] ដោយឡែក អំពើសមគំនិត និង ជាពិសេស អ្នកសមគំនិត យោងតាមវចនានុក្រម Black's Law Dictionary កំណត់និយមន័យថា គឺជា "ជនណាដែលជាប់ពាក់ព័ន្ធតាមវិធីណាក៏ដោយ ជាមួយជនណាម្នាក់ទៀតក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយ ទោះបីជាសហចារីនៅក្នុងកម្រិតទីមួយ ឬ កម្រិតទីពីរ ឬ ក៏ជាបរិវារជនក្តី"[10]។

១១. សេចក្តីអត្ថាធិប្បាយរបស់ ILC ចំពោះគោលការណ៍ VII ពិតជាសំដៅទៅលើ "ផែនការរួម" ប៉ុន្តែនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព *តែប៉ុណ្ណោះ*[11]។ កថាខណ្ឌ ១២៧ នៃសេចក្តីអត្ថាធិប្បាយ

---

[9] *រឿងក្តី អៀង សារី*, សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក អៀង សារី ទៅលើសេចក្តីសង្កេតបន្ថែមរបស់គាត់ ស្តីពីការអនុវត្តន៍ទ្រឹស្តី សហកម្មឧក្រិដ្ឋកម្មរួម ដាក់នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨៖ ត្រូវបានកំណត់ត្រឹមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាទអង្គការសហប្រជាជាតិចូលជាធរមាន ដូចដែលត្រូវបានតវ៉ា/លប់ចោលដោយ ក.ស.ព ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩, កថាខណ្ឌ៩ ("សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក អៀង សារី") ដកស្រង់ Attila Bogdan, *ការទទួលខុសត្រូវឧក្រិដ្ឋកម្មបុគ្គល (Individual Criminal Responsibility)*, 6 INT'L. CRIM. L. REV. 63 (2006) ទំព័រ ៧៥។

[10] BLACK'S LAW DICTIONARY 16 (Bryan A. Garner ed., Westgroup St. Paul Minnesota 1999). *សូមមើលផងដែរ* យោបល់ដាច់ដោយឡែករបស់ចៅក្រម Shahabuddeen នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់ Milutinović និងអ្នកផ្សេងទៀត*, IT-99-37-AR72, សេចក្តីសម្រេចលើពាក្យសុំរបស់ Dragoljub Ojdanić ជំទាស់នឹងយុត្តាធិការ -- *សហកម្មឧក្រិដ្ឋកម្មរួម*, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌ១០៖ "ក្នុងរឿងក្តី *Davies តទល់ ប្រធានរដ្ឋអាជ្ញាសាធារណៈ*; Lord Simonds ... បាននិយាយថាពាក្យ អ្នកសមគំនិត រួមមានមនុស្សដូចខាងក្រោមនេះ... "... អ្នកដែលចូលរួមក្នុងឧក្រិដ្ឋកម្មនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដ៏ជាក់លាក់ ថាតើវាជាគោលការណ៍ ឬជាអ្នកសមគំនិតមុនឬក្រោយពិរុទ្ធហេតុ... ឬជាអ្នកដែលប្រព្រឹត្ត ផ្តល់ឱ្យ ឬផ្តល់ជាជំនួយ និងញុះញង់..."។

[11] របាយការណ៍ ILC, កថាខណ្ឌ១២៦។ កថាខណ្ឌ ៨ នៃសេចក្តីសន្និដ្ឋានបន្ថែមរបស់លោក អៀង សារី ទៅលើសេចក្តីសង្កេតបន្ថែមរបស់គាត់ ស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ដាក់នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨៖ ត្រូវបានកំណត់ត្រឹមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាទអង្គការសហប្រជាជាតិចូលជាធរមាន ដូចដែលត្រូវបានតវ៉ា/លប់ចោលដោយ

របស់ ILC គូសបញ្ជាក់ថា ចុងចោទជាច្រើននាក់ត្រូវបានកាត់ឱ្យជាប់ទោសចំពោះ <u>អំពើសមគំនិត</u> នៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

១២. ទឡ្ហីករណ៍ដំបូងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានជោគជ័យឡើយ ពីព្រោះ ១) គោលការណ៍ VI ចែងបញ្ជាក់អំពី ការទទួលខុសត្រូវផែនការរួម ទាក់ទងចំពោះតែឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពប៉ុណ្ណោះ ២) អំពើសមគំនិត ដូចដែលបានពិភាក្សានៅក្នុងគោលការណ៍ VII គឺខុសគ្នាជាសារវន្តទៅនឹងការទទួលខុសត្រូវផែនការរួម និង ៣) សេចក្តីអត្ថាធិប្បាយចំពោះរបាយការណ៍ ILC មិនបានសំដៅទៅលើ ការទទួលខុសត្រូវផែនការរួម នៅក្នុងបរិបទណាផ្សេងទៀត ក្រៅពីចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពឡើយ។

**គ. ការដកស្រង់ដោយធ្វេសប្រហែសនូវរបាយការណ៍របស់ Spiropoulos ប្រៀបវាដូចជារបាយការណ៍របស់ ILC មិនផ្លាស់ប្តូរការពិតដែលថាមិនមានរបាយការណ៍ណាមួយទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។**

១៣. ដើមបណ្តឹងរដ្ឋប្បវេណីលើកទឡ្ហីករណ៍ថា សហមេធាវីការពារក្តីបានដកស្រង់របាយការណ៍របស់ Spiropoulos ប្រៀបវាដូចជារបាយការណ៍របស់ ILC ដូច្នេះ ធ្វើឱ្យសហមេធាវីការពារក្តីភ្លេចគោលការណ៍ VII ដែលបង្ហាញថា របាយការណ៍របស់ ILC ទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម[12]។ សហមេធាវីការពារក្តីទទួលស្គាល់ថា តាមរយៈការមើលរំលងហួសដោយអចេតនា ខ្លួនបានដកស្រង់របាយការណ៍របស់ Spiropoulos ដោយភាន់ច្រឡំថាជារបាយការណ៍របស់ ILC នៅជើងទំព័រណាមួយ[13]។

---

ក.ស.ព ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ កត់សម្គាល់ថា របាយការណ៍របស់ ILC មិនរាប់បញ្ចូលការទទួលខុសត្រូវផែនការរួមចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ។ បន្ទាប់មកវាថ្លែងថា "[នៅ]ពេលដែល [របាយការណ៍ ILC] ពិតជាបានរួមបញ្ចូលគោលការណ៍ផ្សេងទៀតដែលបានរៀបរាប់ដោយ OCP មិនបានរៀបរាប់ <u>អ្វីដែលត្រូវបានធ្វើឡើងដោយការទទួលខុសត្រូវផែនការរួម"។</u> មេធាវីការពារក្តីទទួលស្គាល់ថា សេចក្តីថ្លែងនេះអាចនាំឱ្យមានការយល់ច្រឡំ និងគួរត្រូវបានព្រាងដោយការបញ្ជាក់/ភាពត្រឹមត្រូវច្រើនជាងមុន។

12 ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ៥-៦។

13 *សូមមើល* សំណើសុំបដិសេធ, ជើងទំព័រ ៣០។

ឯកសារ/ស: ៤៦៧/៦/៦



១៤. របាយការណ៍របស់ Spiropoulos មានតែគោលការណ៍ចំនួនប្រាំប៉ុណ្ណោះ ដែល តាមពិត ស្រដៀងគ្នាយ៉ាងខ្លាំងក្នុងការរៀបឃ្លាប្រយោគទៅនឹងគោលការណ៍ប្រាំដំបូងនៃរបាយការណ៍របស់ ILC[14]។ ការបន្ថែមក្រោយមកទៀតនូវគោលការណ៍ VI និង គោលការណ៍ VII នៅក្នុងរបាយការណ៍របស់ ILC យ៉ាងណាក្តី ពុំបានបង្ហាញថា ILC មានបំណងបញ្ចូល និង ទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម ជាទូទៅ ជាគោលការណ៍ Nuremberg ឡើយ។ គោលការណ៍ VI ដូចដែលបានពិភាក្សារួចហើយ សំដៅតែទៅលើ ការទទួលខុសត្រូវផែនការរួម នៅក្នុងបរិបទ ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ប៉ុណ្ណោះ រីឯគោលការណ៍ VII សំដៅតែទៅលើ អំពើសមគំនិត ប៉ុណ្ណោះ ដែលខុសគ្នាជាសារវន្តពី ការទទួលខុសត្រូវផែនការរួម។ អាស្រ័យហេតុនេះ ការដកស្រង់ឃ្លាប្រយោគមិនត្រឹមត្រូវ ពុំធ្វើឱ្យប៉ះពាល់ដល់គោលជំហររបស់សហមេធាវីការពារក្តី ដែលថារបាយការណ៍របស់ ILC ឥតបានបញ្ជាក់ថា ការទទួលខុសត្រូវផែនការរួម ត្រូវអាចអនុវត្តបានចំពោះ ឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឡើយ។

### ឃ. របាយការណ៍របស់ Spiropoulos ក៏ដូចជារបាយការណ៍របស់ ILC ទទួលស្គាល់ការទទួលខុសត្រូវផែនការរួម ចំពោះតែ ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ប៉ុណ្ណោះ

១៥. ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា របាយការណ៍របស់ Spiropoulos ទទួលស្គាល់

---

[14] គោលការណ៍ប្រាំដែលបានចែងក្នុងរបាយការណ៍ Spiropoulos គឺ៖ ១) ជនណាដែលប្រព្រឹត្ត ឬជាអ្នកសមគំនិតក្នុងការប្រព្រឹត្តិអំពើដែលបង្កើតជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ត្រូវទទួលខុសត្រូវ និងត្រូវផ្តន្ទាទោស។ ២) ការពិតដែលថាច្បាប់ក្នុងស្រុកមិនផ្តន្ទាទោសអំពើមួយដែលជាអំពើឧក្រិដ្ឋអន្តរជាតិ មិនបានធ្វើឱ្យជនដែលរួចខ្លួនពីការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មនោះក្រោមច្បាប់អន្តរជាតិនោះទេ។ ៣)ការពិតដែលថា បុគ្គលម្នាក់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិដើរតួជាប្រធានរដ្ឋ ឬជាមន្ត្រីសាធារណៈ បុគ្គលនោះមិនរួចខ្លួនពីការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិ ឬបន្ធូរការផ្តន្ទាទោសនោះទេ។ ៤) ការពិតដែលថា បុគ្គលម្នាក់បានប្រព្រឹត្តតាមបញ្ជារបស់រដ្ឋាភិបាលខ្លួន ឬតាមបញ្ជារបស់ចៅហ្វាយនាយរបស់ខ្លួន បុគ្គលនោះមិនរួចខ្លួនពីការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិនោះទេ។ ទោះជាយ៉ាងណាក៏ដោយ វាអាចត្រូវបានចាត់ទុកក្នុងការបន្ធូរការផ្តន្ទាទោស ប្រសិនបើយុត្តិធម៌តម្រូវដូច្នេះ។ ៥) បុគ្គលណាដែលត្រូវបានចោទប្រកាន់ដោយឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិមានសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌លើអង្គហេតុនិងអង្គច្បាប់។ *ការបង្កើតគោលការណ៍ Nürnberg -- របាយការណ៍របស់ J. Spiropoulos អ្នករាយការណ៍ពិសេស,* ការស្រង់ចេញពីសៀវភៅប្រចាំឆ្នាំរបស់ គណៈកម្មការច្បាប់អន្តរជាតិ, ១៩៥០, vol II (A/CN.4/22) ("របាយការណ៍ Spiropoulos") ។

ការទទួលខុសត្រូវផែនការរួម[15]។ ការអះអាងនេះផ្អែកទៅលើ "ការវិភាគប្រវត្តិសាស្ត្រនៃរបាយការណ៍របស់ Spiropoulos"[16] និង ផ្អែកទៅលើសេចក្តីអត្ថាធិប្បាយចំពោះរបាយការណ៍នោះ[17]។

១៦. ផ្នែកប្រវត្តិសាស្ត្រនៃរបាយការណ៍របស់ Spiropoulos ពុំបានបង្ហាញថា ការទទួលខុសត្រូវផែនការរួម ត្រូវបានទទួលស្គាល់ជាផ្នែកនៃគោលការណ៍ Nuremberg ឡើយ។ បើទោះបីជាមានរដ្ឋខ្លះបានស្នើឱ្យមានការបកស្រាយទូលំទូលាយអំពី ការទទួលខុសត្រូវផែនការរួម យ៉ាងណាក្តី ក៏នៅក្នុងអំឡុងដំណើរការធ្វើសេចក្តីព្រាងនៃធម្មនុញ្ញ Nuremberg សេចក្តីសន្និដ្ឋាននៃកិច្ចពិភាក្សានៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ១៩៤៥[18] និង ពង្រាងបន្ទាប់ៗទៀត ដែលត្រូវបានបង្ហាញឡើងនៅអំឡុងពេលសន្និសីទនាងទីក្រុងឡុងដ៍[19] បានដាក់កំហិតលើការដាក់ទោសទណ្ឌចំពោះការចូលរួមក្នុង ផែនការរួម ត្រឹមតែរឿងក្តីទាំងឡាយ ដែលមានគោលបំណងក្នុងការត្រួតត្រាប្រទេសជាតិមួយតាមមធ្យោបាយសង្គ្រាមឈ្លានពានប៉ុណ្ណោះ។

១៧. លើសពីនេះ ធម្មនុញ្ញ Nuremberg គ្រាន់តែបានរៀបរាប់យ៉ាងជាក់លាក់ប៉ុណ្ណោះ អំពី ការទទួលខុសត្រូវផែនការរួម ពេលពិពណ៌នាអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព (មាត្រា ៦(ក))។ ការទទួលខុសត្រូវផែនការរួម ពុំត្រូវបានលើកឡើងនៅក្នុងមាត្រា ៦(ខ) ទេ មាត្រានេះស្តីពីឧក្រិដ្ឋកម្មសង្គ្រាម ហើយមាត្រា ៦(គ) ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[20]។ បើទោះបីជាមាត្រា ៦ ក្នុងកថាខណ្ឌ

15 ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រង់កថាខណ្ឌ ៧-១៣។

16 *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨-១២។

17 *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៣។

18 របាយការណ៍ Spiropoulos ត្រង់កថាខណ្ឌ១៧ ទាញអាគតដ្ឋានកំណត់ហេតុសន្និសីទ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៤៥ ទំព័រ ៣២៨។

19 ចំពោះសេចក្តីព្រាងចក្រភពអង់គ្លេស ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៤៥ *សូមមើល* របាយការណ៍ Spiropoulos កថាខណ្ឌ២០ ចំពោះសេចក្តីព្រាងអាមេរិកកាំងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៤៥ *សូមមើល ជើងទំព័រខាងលើ* ទំព័រ២២។

20 *សូមមើល* ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ មាត្រា ៦(ក) "**ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព៖** មានដូចជា ការរៀបផែនការ ការរៀបចំ ការចូលជាសមាជិក ឬការស៊ើឈ្នួលធ្វើសង្គ្រាមឈ្លានពាន ឬសង្គ្រាមប្រឆាំងនឹងសន្ធិសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង ឬ ការធានា ឬ ការចូលរួមក្នុងផែនការណ៍ទូទៅ ឬការសមគំនិតចំពោះការសម្រេចអំពើណាមួយដូចរៀបរាប់ខាងមុខនេះ។ (ខ) **ឧក្រិដ្ឋកម្មសង្គ្រាម៖** មានដូចជា ការរំលោភទៅលើច្បាប់ ឬទម្លាប់នៃសង្គ្រាម។ ដោយមិនត្រូវបានកំណត់ការរំលោភទាំងនោះត្រូវរួមបញ្ចូល មនុស្សឃាដ ការធ្វើទុក្ខបុកម្នេញ ឬការនិរទេសទៅឱ្យធ្វើការងារជាទេសករ ឬសម្រាប់

ចម្លើយតបរបស់អៀង សារី ទៅនឹងចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើសុំឱ្យដាក់ទណ្ឌកម្ម

ចុងក្រោយរបស់វា (ដែលស្ថិតនៅបន្ទាប់ការពិពណ៌នាអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) គូសបញ្ជាក់ថា "មេដឹកនាំ អ្នករៀបចំ អ្នកញុះញង់ និង អ្នកសមគំនិត ដែលចូលរួមក្នុងការតាក់តែង ឬ ការអនុវត្តផែនការរួម ឬ ការសមគំនិត ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងប៉ុន្មានខាងលើ គឺជាអ្នកទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលប្រព្រឹត្តឡើងដោយជនទាំងឡាយណា ក្នុងការអនុវត្តន៍ផែនការនោះក្តី" សាលក្រម Nuremberg បានកំណត់ព្រំដែនយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវផែនការរួម ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។ សាលក្រម Nuremberg ពុំអើពើចំពោះការចោទប្រកាន់ "ដែលថាជនជាប់ចោទបានឃុបឃិតប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ឡើយ ហើយសាលក្រមនេះពិចារណាតែអំពី "ផែនការរួមក្នុងការរៀបចំ ការផ្តួចផ្តើម និង ការធ្វើសង្គ្រាមឈ្លានពាន[21]" ប៉ុណ្ណោះ។

---

គោលបំណងផ្សេងៗ ចំពោះប្រជាជននៃឬក្នុងទឹកដីដែលគ្រប់គ្រង មនុស្សឃាដ ឬការធ្វើទុក្ខបុកម្នេញដល់ឈ្លើយសឹក ឬមនុស្សនៅសមុទ្រ ការសម្លាប់ចំណាប់ខ្មាំង ការប្លន់យកទ្រព្យសម្បត្តិឯកជនឬសាធារណៈ ការបំផ្លិចបំផ្លាញទីក្រុង ទីប្រជុំជន ឬភូមិ ឬការបង្ខិនបង្ខោចដែលមិនចាំបាច់ដោយតម្រូវការយោធា។ (គ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ មានដូចជា មនុស្សឃាដ ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមជនស៊ីវិលណាមួយ មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម។ ឬ ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ជាតិសាសន៍ ឬសាសនា ក្នុងការប្រតិបត្តិចំពោះ ឬ ក្នុងការជាប់ទាក់ទងជាមួយឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការនៃតុលាការនេះ ថាតើជាការរំលោភច្បាប់ក្នុងស្រុកនៃប្រទេសដែលបានប្រព្រឹត្តឬអត់"។ អ្នកដឹកនាំ អ្នករៀបចំ អ្នកញុះញុង និង អ្នកសមគំនិតចូលរួមក្នុងការបង្កើត ឬការប្រតិបត្តិនៃផែនការណ៍ទូទៅមួយ ឬការរួមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មរៀបរាប់ពីមុន ត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលបានធ្វើឡើង ឬត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលបានធ្វើឡើងដោយបុគ្គលណាមួយក្នុងការអនុវត្តផែនការនោះ។ មាននៅ http://avalon.law.yale.edu/imt/imtconst.asp#art6 ។ *សូមមើលផងដែរ* Henri Donnedieu de Vabres, *The Nuremberg Trail and the Mondern Principles of International Criminal Law in* PERSPECTIVES ON THE NUREMBERG PRINCIPLES 213, 249 (Oxford University Press, G. Mettraux (ed.), 2008) ។

21 សាលក្រមរបស់ តុលាការយោធាអន្តរជាតិ ចំពោះការជំនុំជម្រះក្តីនៃ German Major War Criminals, Nuremberg, ថ្ងៃទី ៣០ ខែកញ្ញា និងថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦, London H.S.S.O. ផ្សេងៗលេខ 12 (1946), ត្រង់ទំព័រ៤៤។ *សូមមើលផងដែរ* សាលក្រមរបស់តុលាការយោធា សម្រាប់ Far East, ត្រង់ទំព័រ៣៤ ដែលចែងថា "ធម្មនុញ្ញមិនបានផ្តល់យុត្តាធិការណាមួយទាក់ទងនឹងការសមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ជាជាងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។ មិនមានការបញ្ជាក់អំពីឧក្រិដ្ឋកម្មនៃការសមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមដែលសន្មត់។ តួនាទីនេះត្រូវបានទទួលយកដោយរដ្ឋអាជ្ញា និងមិនមានការផ្តន្ទាទោសត្រូវបានធ្វើក្រោមបទចោទទាំងនេះទេ។ ដូច្នេះ បទចោទទាំងនេះនឹងត្រូវលើកលែង"។

E3/??, ៦97/9/6



១៨. សេចក្តីសន្និដ្ឋានដដែលនោះ គឺថា ធម្មនុញ្ញ Nuremberg និង សាលក្រមនោះ បានកំណត់យ៉ាងច្បាស់ពី ការទទួលខុសត្រូវផែនការរួម ត្រឹមតែជា ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ត្រូវបានសម្រេចឡើង នៅក្នុងឯកសារការងារចុងក្រោយស្តីពីការគាក់តែងគោលការណ៍ Nuremberg ដែលចេញដោយអនុគណៈកម្មាធិការនេះ ដែលត្រូវបានតែងតាំងដោយ ILC[22]។ របាយការណ៍ Spiropoulos បានយកឯកសារការងារចុងក្រោយនេះធ្វើជាមូលដ្ឋាន[23]។

១៩. ការទទួលខុសត្រូវផែនការរួម មិនត្រូវបាននិទ្ទេសនៅក្នុងគោលការណ៍ទាំងប្រាំនៃរបាយការណ៍ Spiropoulos នេះឡើយ។ វាត្រូវបាននិទ្ទេសតែនៅក្នុងសេចក្តីអត្ថាធិប្បាយចំពោះគោលការណ៍ I[24] និងត្រង់ផ្នែកស្តីពីឧក្រិដ្ឋកម្មប៉ុណ្ណោះ[25]។ នៅក្នុងចំណុចទាំងពីរនោះ ការទទួលខុសត្រូវផែនការរួម ត្រូវបានកំណត់ត្រឹមតែជាបរិបទនៃការរៀបចំ ការផ្តួចផ្តើម និង ការធ្វើសង្គ្រាមឈ្លានពានប៉ុណ្ណោះ។

២០. ទឡ្ហីករណ៍ដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា របាយការណ៍ Spiropoulos ទទួលស្គាល់ថា "សាលាក្តីនោះបានអនុវត្តវិធានខ្លះស្តីពី អំពើសមគំនិត ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រោះជនជាប់ចោទមួយចំនួនត្រូវកាត់ឱ្យជាប់ទោស ចំពោះការដាក់បញ្ញា[26]"នោះ គឺជាការភ័ន្តច្រឡំ។ ប្រសិនបើសម្រង់ដែលសម្រាំងនេះត្រូវបានអានក្នុងបរិបទនៃរបាយការណ៍ Spiropoulos ទាំងមូល ហើយត្រូវបានបកស្រាយជាលក្ខណៈប្រព័ន្ធវិញនោះ មានតែសេចក្តីសន្និដ្ឋានមួយប៉ុណ្ណោះដែលអាចទាញបង្ហាញ ៖ នោះគឺ អំពើសមគំនិត តែមិនមែនជាការទទួលខុសត្រូវផែនការរួម ដែលត្រូវបានអនុវត្តចំពោះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម ឡើយ។

---

[22] *ការបង្កើតគោលការណ៍ដែលត្រូវបានទទួលស្គាល់ក្នុងតុលាការ* Nümberg *និង សាលក្រមនៃសេក្តីព្រៀងរបស់តុលាការ ដែលត្រូវបានស្នើដោយអនុគណៈកម្មាធិការ ស្តីពីការបង្កើតគោលការណ៍* Nümberg *ភ្ជាប់ក្នុងឯកសារ A/CN.4/SR.25, fn.9, សូមមើល* ជាពិសេសការបង្កើតគោលការណ៍៣ ដែលបានស្នើឡើង។

[23] របាយការណ៍ Spiropoulos កថាខណ្ឌ ៤១-៤២។

[24] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៣(២)(i)-(iii)។

[25] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៥(ក) (ii)។

[26] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រង់កថាខណ្ឌ ១៣។

### ង. អង្គហេតុដែលថា របាយការណ៍ ILC រក្សាទុកពាក្យ "អំពើសមគំនិត" នៅក្នុងគោលការណ៍ VII មិនមានន័យថា ខ្លួនទទួលស្គាល់ ការទទួលខុសត្រូវផែនការរួម ឡើយ

២១. ដើមបណ្តឹងរដ្ឋប្បវេណីបានលើកទឡ្ហីករណ៍ថា ការតាក់តែងគោលការណ៍ទាំងអស់នេះ ដែលមានចែងក្នុងរបាយការណ៍ Spiropoulos គ្មានសិទ្ធិអំណាចខាងផ្លូវច្បាប់អ្វីឡើយ ហើយ សេចក្តីសម្រេចរបស់ ILC ក្នុងការបញ្ចូលគោលការណ៍ VII ថ្វីបើមានរបាយការណ៍ Spiropoulos រួចហើយក្តី បង្ហាញថាសេចក្តីសម្រេចនោះបានពិចារណាថា ការទទួលខុសត្រូវផែនការរួមថា ជាផ្នែកមួយនៃគោលការណ៍ Nuremberg[27]។

២២. សហមេធាវីការពារក្តីយល់ស្របថា របាយការណ៍ Spiropoulos មានតែតួនាទីប្រឹក្សាយោបល់ប៉ុណ្ណោះ ក្នុងការរៀបចំរបាយការណ៍ ILC ឡើង។ អង្គហេតុដែលថា ILC បានសម្រេចបញ្ចូលគោលការណ៍ VII យ៉ាងណាក្តី មិនធ្វើឱ្យមានការប្រែប្រួលអ្វីឡើយទៅលើការពិតដែលថា គោលការណ៍ Nuremberg នេះគ្រាន់តែរាប់បញ្ចូល ការទទួលខុសត្រូវផែនការរួម ចំពោះ ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ប៉ុណ្ណោះ។ គោលការណ៍ VII នៃគោលការណ៍ Nuremberg និយាយអំពី អំពើសមគំនិត មិននិយាយអំពី ការទទួលខុសត្រូវផែនការរួម ឡើយ។ ដូច្នេះ ដូចដែលបានពិភាក្សារួចមក ហើយនៅត្រង់ផ្នែក ខ យើងឃើញថា គោលការណ៍ទាំងពីរនេះ ជាមូលដ្ឋាន មានលក្ខណៈពុំដូចគ្នាទេ ហើយក៏ពុំអាចផ្លាស់ប្តូរជំនួសគ្នាបានឡើយ។

## III. **សន្និដ្ឋាន និង សំណូមពរ**

២៣. ដើមបណ្តឹងរដ្ឋប្បវេណីខកខានពុំបាននិយាយទៅដល់បញ្ហាស្នូលនៃការស្នើសុំដាក់ទណ្ឌកម្ម ដែលជាទណ្ឌកម្មត្រូវបានស្នើសុំប្រឆាំងនឹងការិយាល័យសហព្រះរាជអាជ្ញា ចំពោះការបំភាន់ដោយចេតនាឱ្យតុលាការយល់ខុស តាមការមិនបង្ហាញដោយចេតនានូវសេចក្តីសម្រេច ៤៨៨(V) នៃមហាសន្និបាតអង្គការសហប្រជាជាតិ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីបែរជាជ្រើសរើសធ្វើការផ្តោតយកចិត្តទុកដាក់របស់ខ្លួន លើបញ្ហានៃការដកស្រង់ពុំត្រឹមត្រូវដែលពុំមែនជារឿងដុំកំភួនទៅវិញ ដែលដូចដែលបានបង្ហាញក្នុងចម្លើយតបនេះស្រាប់ ពុំប៉ះពាល់ដល់ទឡ្ហីករណ៍ ដែលសហមេធាវីការពារ

---

[27] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១៤-១៦។

ឯកសារ: D97/9/6



ក្តីបានលើកឡើងថា គោលការណ៍ Nuremberg ពុំរាប់បញ្ចូលនូវ ការទទួលខុសត្រូវផែនការរួម ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឡើយ។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដូចដែលបានបញ្ជាក់ជូនខាងលើ សហមេធាវីការពារក្តីស្នើ ដោយគោរព សុំឱ្យសហចៅក្រមស៊ើបអង្កេតមេត្តាទទួលយកសំណូមពរនេះ ដូចមានថ្លែងស្រាប់នៅក្នុងសំណើសុំឱ្យដាក់ទណ្ឌកម្ម។

សូមលោកមេត្តាទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៥** ខែកញ្ញា ឆ្នាំ **២០០៩**

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**